# I. សេចក្ដីផ្ដើម :

ឆ្នាំសិក្សា២០០៤-០៥នេះ ជាឆ្នាំចុងក្រោយនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ និងជាដំណាក់កាលចាប់ផ្ដើមរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-១០ អោយស៊ីសង្វាក់គ្នាជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-១០ របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៣នៃរដ្ឋសភា ។ ដូច្នេះស្ថានភាពរីកចំរើនជាក់ស្ដែង និងវិវត្តទៅមុខរបស់វិស័យអប់រំក្នុងដំណាក់កាលនេះ មានអត្ថន័យសំខាន់ណាស់សម្រាប់ធ្វើជាមូលដ្ឋាន បង្អែកដ៏រឹងមាំ បំរើអោយការវិភាគគោលនយោបាយអប់រំ ក៏ដូចជាការសម្រេចចិត្តនានាលើយុទ្ធសាស្ត្រចាំបាច់ដែលត្រូវអនុវត្តក្នុងដំណាក់កាលបន្តបន្ទាប់ទៀត ។

វត្ថុបំណងសំខាន់របស់របាយការណ៍នេះ គឺធ្វើការវាយតម្លៃលើការរីកចំរើននៃសកម្មភាពបំពេញការងារវិស័យអប់រំទាំងមូល តាមរយៈការប្រមូលនិងបូកសរុបលទ្ធផលនៃការអនុវត្តផែនការអប់រំរបស់ខេត្ត-ក្រុង និងរបស់នាយកដ្ឋានជំនាញទាំងអស់ ដែលបានខិតខំចងក្រងជារបាយការណ៍និងបានផ្ញើជូនក្រសួងអប់រំ យុវជន និងកីឡានាដំណាច់ឆ្នាំសិក្សាកន្លងមកនេះ ។ របាយការណ៍របស់ខេត្ត-ក្រុងនិងរបស់នាយកដ្ឋានជំនាញ បានឆ្លុះបញ្ចាំងអោយឃើញពីកម្រិតទទួលខុសត្រូវក្នុងការអនុវត្តនិងឈានទៅសម្រេចគោលនយោបាយអប់រំ ដែលបានកំណត់ទុកក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក៏ដូចជាផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០០៣-១៥ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍រួមរបស់សកលលោក ជាពិសេសគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ប្រទេសកម្ពុជាផ្ទាល់ ។

របាយការណ៍ស្ដីពីការបំពេញការងាររបស់វិស័យអប់រំនេះ ពិតជាមានសារៈសំខាន់ណាស់ក្នុងការវិភាគអំពីនិន្នាការវិវឌ្ឍន៍នានារបស់វិស័យទាំងមូលដែលជាផលប៉ះពាល់នៃការអនុវត្តកំណែទម្រង់វិស័យអប់រំ ជាពិសេសផលប៉ះពាល់នៃសេចក្ដីថ្លែងការណ៍ពីគោលបំណងរួមដែលបានឯកភាពគ្នារវាងរាជរដ្ឋាភិបាលនិងភាគីផ្ដល់ជំនួយនានា ដែលក្នុងនោះរួមមានៈ ផលប៉ះពាល់នៃគោលនយោបាយផ្ទេរការអនុវត្តភាពជាអ្នកផ្ដល់ជំនួយ ទៅជាការអនុវត្តភាពជាដៃគូក្នុងវិស័យអប់រំ ក៏ដូចជាផលប៉ះពាល់ជាវិជ្ជមាននៃការពង្រឹងភាពជាដៃគូ ព្រមទាំងផលប៉ះពាល់នៃការអនុវត្តភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជានិងក្រសួងអប់រំ យុវជន និងកីឡា តាមគោលការណ៍អភិក្រមគ្រប់គ្រងទូទាំងវិស័យអប់រំ ។

មិនតែប៉ុណ្ណោះ របាយការណ៍នេះក៏បានឆ្លុះបញ្ចាំងអោយឃើញពីផលប៉ះពាល់នៃការអនុវត្តថវិកា ដែលបានទទួលស្គាល់ថាជាស្ពានឈានទៅសម្រេចគោលនយោបាយអប់រំនានា ដែលបានកំណត់ទុកក្នុងដំណាក់កាលនៃកំណែទម្រង់វិស័យអប់រំ ។ម្យ៉ាងទៀត របាយការណ៍បំពេញការងារវិស័យអប់រំនេះ ពិតជាបង្ហាញអោយឃើញអំពីលទ្ធផលនិងផលប៉ះពាល់នៃការអនុវត្តគោលនយោបាយសំខាន់ៗរួមមានៈ ១). គោលនយោបាយធានាសមធម៌នៃការទទួលបានសេវាអប់រំសម្រាប់កុមារកម្ពុជាគ្រប់រូប។ ២). គោលនយោបាយពង្រឹងគុណភាពនិងប្រសិទ្ធភាពសេវាអប់រំគ្រប់ភូមិសិក្សា។ ៣). គោលនយោបាយអភិវឌ្ឍស្ថាប័ននិងកសាងសមត្ថភាពមន្ត្រីដើម្បីអនុវត្តវិមជ្ឈការការងារអប់រំ ។

តាមរយៈរបាយការណ៍នេះ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយដៃគូអភិវឌ្ឍន៍នានាដែលកំពុងបំពេញការងារក្នុងវិស័យអប់រំ ពិតជាអាចរកឃើញបទពិសោធន៍ការងារល្អៗដែលត្រូវបន្តអនុវត្តនៅពេលអនាគតខាងមុខ ។